ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីព្យាបាលជាសះស្បើយ ០១នាក់ និង មិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី
# នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

## ១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- **ចំនួនអ្នកព្យាបាលជាសះស្បើយ**សរុបទូទាំងប្រទេស មានចំនួន **១២៦នាក់** (ស្មើនឹង ៩៨,៤៤% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៣៩នាក់ និងបុរស ៨៧នាក់
- **អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត** មានចំនួន ០២នាក់ (ជាបុរស)៖
  - បុរសជនជាតិខ្មែរ ០២ នាក់ ដែលបានវិលត្រឡប់មកពីប្រទេសឥណ្ឌូណេស៊ី
- **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់**នៅទូទាំងប្រទេស សរុបចំនួន **១២៨នាក់** (ស្ត្រី ៣៩នាក់ និងបុរស ៨៩នាក់)។

## ២. ករណីជាសះស្បើយ៖ មាន ០១នាក់

បុរសជនជាតិខ្មែរ អាយុ ២៦ឆ្នាំ មានទីលំនៅនៅឃុំ កំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត ជាអ្នកដំណើរដែលបានវិលត្រឡប់មកពីប្រទេសហ្វីលីពីន បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២ដង និងត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

## ៣. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី៖ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព


ទីស្នាក់ការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: [illegible] ៨៨៤ ៩០៩

និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

## ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២៨ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២៨ ករណី




ប្រភព៖ ក្រសួងសុខាភិបាល